**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេច កត្តាព្រឹទ្ធបណ្ឌិត**

**ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**

**សម្តេចតេជោ នាយករដ្ឋមន្ត្រី និងសម្តេច កត្តាព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសទិវា **ចូលឆ្នាំសកល ឆ្នាំ ២០១៦** នេះ យើងខ្ញុំទាំងអស់គ្នា ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំង នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះមេត្តាប្រោសប្រទានប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និង**សម្តេច កត្តាព្រឹទ្ធបណ្ឌិត** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមបានប្រកបដោយសុខភាពល្អបរិបូរណ៍ជន្មាយុយឺនយូរ និងទទួលបានជោគជ័យធំៗថ្មីៗ ថែមទៀត ក្នុងបេសកកម្មដឹកនាំរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាទទួលបាននូវសុខសន្តិភាព ស្ថិតក្នុងឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីពេញលេញ និងមានការអភិវឌ្ឍន៍រីកចម្រើនលើគ្រប់វិស័យ។

យើងខ្ញុំទាំងអស់គ្នា ជាកងយោធពលខេមរភូមិន្ទ សូមចូលរួមអបអរសាទរគាំទ្រយ៉ាងក្លៀវក្លា និងកក់ក្តៅបំផុតចំពោះជោគជ័យនិងសមិទ្ធផលធំៗជាច្រើនដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងឆ្នាំកន្លងមកបានលើកស្ទួយកិត្យានុភាព កិត្តិយស កិត្តិស័ព្ទ និងមុខមាត់ នៃព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែខ្ពស់ត្រដែតល្បីរន្ទឺលើឆាកអន្តរជាតិ។

កត្តាទាំងនេះកងយោធពលខេមរភូមិន្ទ និងប្រជាជនកម្ពុជាទាំងមូល មើលឃើញកាន់តែច្បាស់ថែមទៀត នូវតួនាទីដែលមិនអាចខ្វះបានរបស់ **សម្តេច** ទាំងពេលបច្ចុប្បន្ននិងទៅអនាគត ដើម្បីដឹកនាំមាតុភូមិកម្ពុជាឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ និងកាន់តែសម្បូររុងរឿងថែមទៀតលើគ្រប់វិស័យ។

កងយោធពលខេមរភូមិន្ទ និងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសមានក្តីសង្ឃឹម និងមានជំនឿជឿជាក់លើការដឹកនាំ និងសូមគាំទ្របេក្ខភាពរបស់ **សម្តេច** ជានាយករដ្ឋមន្ត្រី សម្រាប់អាណត្តិក្រោយៗទៀត។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាទីគោរព ដ៏ខ្ពង់ខ្ពស់ មេត្តាទទួលនូវគោរវភក្តីភាពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**